រាជរដ្ឋាភិបាល
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia
លេខ..៤៣៩/១០.ក.អ.ក / គ.ជ.នា

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
*Nation - Religion - King*

រាជធានីភ្នំពេញ ថ្ងៃទី..៣០..ខែ..មេសា..ឆ្នាំ២០១០

**គោរពជូន**

**សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : របាយការណ៍ស្តីពីលទ្ធផលនៃកិច្ចប្រជុំលើកទី១៦ របស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (Government-Development Partner Coordination Committee-GDCC) នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០

**ឯកសារភ្ជាប់** : - សេចក្តីព្រាងបញ្ចប់តារាងសូចនាករតាមដានរួមគ្នាសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ (Joint Monitoring Indicators-JMIs)

- ក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ២០១០-២០១២ (Multi-year Indicative Financing Framework-MYIFF)

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ខ្ញុំបានដឹកនាំកិច្ចប្រជុំលើកទី ១៦ នៃគណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នារសៀលថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១០ នៅវិមានរដ្ឋាភិបាល (ទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) ។ ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី ០៥រូប ឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកនៃក្រសួងនិងស្ថាប័នរាជរដ្ឋាភិបាល ប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំង១៩ក្រុមការងារ ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត ប្រធានស្ថាប័នផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ព្រមទាំងមន្ត្រីបច្ចេកទេស ទាំងខាងរាជរដ្ឋាភិបាល និងខាងដៃគូអភិវឌ្ឍន៍ប្រមាណ២០០រូបបានចូលរួម ។

ដូចសព្វមួយដង ការត្រៀមរៀបចំការងារសម្រាប់កិច្ចប្រជុំស្ថិតក្រោមការសម្របសម្រួលរបស់ឯកឧត្តម **ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) ដែលជាលេខាធិការដ្ឋាន GDCC និងក្រោមការដឹកនាំរបស់ខ្ញុំផ្ទាល់ ។ របៀបវារៈសម្រាប់កិច្ចប្រជុំលើកទី១៦នេះ បានផ្តោតលើប្រធានបទសំខាន់ពីរ គឺ :

១- វឌ្ឍភាពក្នុងការរៀបចំយន្តការ «ចំណាយប្រតិបត្តិការអាទិភាព (Priority Operating Costs--POC) »

២- វឌ្ឍនភាពក្នុងការត្រៀមរៀបចំវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ពិសេស សូចនាករតាមដានរួមគ្នា និងក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ២០១០-២០១២ ។

ខ្ញុំសូមអនុញ្ញាតរាយការណ៍ជូន **សម្តេចនាយករដ្ឋមន្ត្រី** អំពីលទ្ធផលសំខាន់ៗនៃកិច្ចប្រជុំដូចខាងក្រោម :

ក- **<u>ចំណាយប្រតិបត្តិការអាទិភាព</u>** : មុននឹងចាប់ផ្ដើមការពិភាក្សាលើរបៀបវារៈនេះ ខ្ញុំបានគូសបញ្ជាក់ជូនអង្គប្រជុំ ក្នុងឋានៈខ្ញុំជាប្រធានគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ អំពីគោលការណ៍គ្រឹះ- *«គោលការណ៍សមធម៌»*នៃការសម្រេចចិត្តខាងនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបញ្ចប់ការអនុវត្តន៍យន្តការ «កន្សោមអាទិភាពនិងប្រាក់លាភការដោយផ្អែកលើលទ្ធផលការងារ» ។ នេះគឺជាគោលការណ៍ស្នូលនៅក្នុងយុទ្ធសាស្ត្រជាតិ យុទ្ធសាស្ត្រតាមវិស័យ ព្រមទាំងនៅក្នុងគ្រប់ការដ្ឋានកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ដែល **សម្ដេច នាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ជាច្រើនលើក ហើយនេះក៏ជាគោលការណ៍ស្នូលនៃ «យុទ្ធសាស្ត្រចតុកោណ» ផងដែរ ។ ការរៀបចំយន្តការស្ដីពី «ចំណាយប្រតិបត្តិការអាទិភាព» ក៏ត្រូវតែប្រកាន់ខ្ជាប់នូវ «គោលការណ៍សមធម៌» នេះ រួមជាមួយនឹងគោលការណ៍មូលដ្ឋានដទៃទៀតនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ដូចជា គោលការណ៍ស្ដីពី «ឯកភាពនៃប្រព័ន្ធរដ្ឋបាល ការធ្វើសុខដុមនីយកម្ម ប្រសិទ្ធភាព និងចីរភាព» ជាដើម ។ បន្ទាប់មកទៀត ឯកឧត្ដម **ង៉ោ ហុងលី** អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានរាយការណ៍អំពីវឌ្ឍនភាពក្នុងការរៀបចំយន្តការ «ចំណាយប្រតិបត្តិការអាទិភាព» ពិសេសលើគោលការណ៍គន្លឹះ ដែលគណៈ-កម្មាធិការដឹកនាំការងារបានឯកភាពជាមួយនឹងដៃគូអភិវឌ្ឍន៍ នៅក្នុងកិច្ចប្រជុំនាថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១០ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល និងរវាងរាជរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ក្នុងកម្រិតបច្ចេកទេសជាច្រើនលើកច្រើនសារកន្លងមក ។

បន្ទាប់ពីបានពិភាក្សាយ៉ាងផុសផុលមក ភាគីទាំងសងខាងបានឯកភាពសារជាថ្មីម្ដងទៀតថា «ចំណាយប្រតិបត្តិការអាទិភាព» គឺជាវិធានការណ៍អន្តរកាល និងចំពោះមុខ សម្រាប់ជំនួសឱ្យយន្តការដែលត្រូវបានបញ្ចប់ ។ ចំណាយប្រតិបត្តិការអាទិភាពនេះមិនមែនជាផ្នែកមួយនៃប្រាក់បៀវត្សរ៍ ឬប្រាក់លើកទឹកចិត្ត និងប្រាក់ឧបត្ថម្ភបន្ថែមលើប្រាក់បៀវត្សរ៍ឡើយ ហើយត្រូវបញ្ចប់នៅពេលដែលគម្រោងត្រូវបញ្ចប់ ។ ចំណាយប្រតិបត្តិការអាទិភាពអាចចាប់ផ្ដើមអនុវត្ត ចាប់ពីថ្ងៃទី០១ ខែកក្កដាខាងមុខ បន្ទាប់ពីក្រុមការងារកម្រិតបច្ចេកទេសរៀបចំបញ្ចប់ និងឯកភាពជាមួយនឹងដៃគូអភិវឌ្ឍន៍លើកម្រិតនៃចំណាយប្រតិបត្តិការ រួមជាមួយនឹងយន្តការលំអិតសម្រាប់អនុវត្ត ។

ដោយឡែក កំណែទម្រង់បៀវត្សរ៍ (Compensation Reform) ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់រដ្ឋបាលសាធារណៈ គឺជាការងាររបស់រដ្ឋដែលមានលក្ខណៈអចិន្ត្រៃយ៍ និងយូរអង្វែង ហើយជាការងារដាច់ដោយឡែកពីចំណាយប្រតិបត្តិការអាទិភាព ។ បញ្ហាទាំងពីរនេះមិនជាប់ទាក់ទងគ្នាឡើយ ។ ការរៀបចំកំណែទម្រង់បៀវត្សរ៍ត្រូវផ្អែកលើគោលការណ៍សំខាន់ៗ ៥ គឺ : កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ប្រសិទ្ធភាពការងារ សមធម៌ការឯកភាព និងចីរភាពក្នុងរដ្ឋបាលសាធារណៈ ។ ដូចនេះ ទាមទារត្រូវពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ និងរៀបចំជាជំហានៗ ព្រមទាំងមានពេលវេលាសមស្របផងដែរ ។ ឯកឧត្ដម ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ តំណាងឱ្យដៃគូអភិវឌ្ឍន៍បានសួរអំពីលទ្ធភាពក្នុង «ការអនុវត្តន៍សាកល្បងតាមស្ថាប័នមួយចំនួន» នៅពេលដែលរាជរដ្ឋាភិបាលបានរៀបចំកំណែទម្រង់បៀវត្សរ៍រួច ។ លើបញ្ហានេះ ឯកឧត្ដម អគ្គលេខាធិការក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានបំភ្លឺថា ដោយប្រព័ន្ធបៀវត្សរ៍របស់យើងបានអនុវត្តតាមគំរូ «ប្រព័ន្ធអជីព» យើងពិបាកនឹងអនុវត្តសាកល្បងតាមស្ថាប័នមួយចំនួន ព្រោះការអនុវត្តន៍បែបនេះអាចទំនាស់នឹងគោលការណ៍ «សមធម៌» ក្នុងរដ្ឋបាលសាធារណៈ ។

ខ- **<u>សូចនាករតាមដានរួមគ្នា</u>** : អង្គប្រជុំបានពិភាក្សានិងឯកភាពលើសេចក្ដីព្រាងបញ្ចប់នៃសូចនាករតាមដានរួមគ្នាសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ លើកលែងតែសូចនាករតាមដានរួមគ្នា

ស្តីអំពីកំណែទម្រង់រដ្ឋបាលសាធារណៈ ។ សូចនាករនេះបានកំណត់កិច្ចការមួយចំនួនដែលត្រូវអនុវត្តសម្រាប់ឈាន ទៅរៀបចំកំណែទម្រង់បៀវត្សរ៍ (Compensation Reform) ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ។ ទោះបីសូចនាករនេះត្រូវបានពិភាក្សានិងឯកភាពក្នុងកម្រិតបច្ចេកទេសរួចហើយក៏ដោយ ក៏ដៃគូអភិវឌ្ឍន៍បាន ស្នើឱ្យមានការពិភាក្សា និងអនុមតិពីកម្រិតនយោបាយបន្ថែមទៀត ។ ដូចខ្ញុំបានរាយការណ៍អំពីវឌ្ឍនភាពក្នុង ការត្រៀមរៀបចំវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ជូន **សម្តេច នាយករដ្ឋមន្ត្រី** តាមលិខិត លេខ៥០១/១០ របស់ ក.អ.ក/គ.ជ.នា ចុះថ្ងៃទី២១ខែមេសាឆ្នាំ២០១០ ដំណើរការនៃការរៀបចំសូចនាករតាមដាន រួមគ្នានេះស្ថិតក្រោមការដឹកនាំ និងភាពជាម្ចាស់ទាំងស្រុងរបស់រាជរដ្ឋាភិបាល ដោយប្រើប្រាស់យ៉ាងពេញលេញ និងមានប្រសិទ្ធភាពនូវយន្តការក្រុមការងារបច្ចេកទេសចម្រុះរបស់រាជរដ្ឋាភិបាល ។ ក្រោមការសម្របសម្រួល របស់ឯកឧត្តម **ឈឿន យ៉ាណារ៉ា** អគ្គលេខាធិការនៃវេទិកា ក.អ.ក/គ.ជ.នា បានធ្វើសំយោគនូវសំណើ សូចនាករតាមដានរួមគ្នាថ្មី ដែលបានស្នើដោយប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំង១៩ក្រុម ហើយបាន ពិភាក្សានិងឯកភាពក្នុងកម្រិតបច្ចេកទេសជាមួយក្រុមការងារបច្ចេកទេសទាំងអស់ មុននឹងស្នើជូនកិច្ចប្រជុំគណៈ-កម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ លើកទី១៦នេះ ។ ដូចគ្នានឹងការរៀបចំសម្រាប់ វេទិកាលើកទី២ រាជរដ្ឋាភិបាលបានប្រកាន់យកគោលការណ៍ច្បាស់លាស់ថា រាល់សំណើសុំផ្លាស់ប្តូរសូចនាករ ត្រូវពិគ្រោះយោបល់និងទទួលការឯកភាពជាមុន ពីប្រធានក្រុមការងារបច្ចេកទេស ។ អនុវត្តតាមគោលការណ៍ នេះ ទើបយើងរក្សាបាននូវតម្លៃរបស់យន្តការក្រុមការងារបច្ចេកទេសចម្រុះ ពង្រឹងភាពជាម្ចាស់ និងភាពដឹកនាំ ។ ក្នុងឋានៈជាប្រធានវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣នេះ ខ្ញុំបានតាមដានកិច្ចដំណើរការ នេះជាប្រចាំ ហើយយល់ថាកិច្ចដំណើរការនេះពិតជាឆ្លុះបញ្ចាំងនូវភាពជាម្ចាស់កាន់តែរឹងមាំរបស់រាជរដ្ឋាភិបាល តាមរយៈក្រុមការងារបច្ចេកទេសចម្រុះ ។ ខ្ញុំសូមជូនភ្ជាប់មកជាមួយនូវសេចក្តីព្រាងបញ្ចប់នៃសូចនាករតាមដាន រួមគ្នា ដែលនឹងត្រូវដាក់ជូនវេទិកាលើកទី៣ ខាងមុខនេះ ។

គ- **<u>ក្របខ័ណ្ឌហិរញ្ញប្បទានណែនាំពហុឆ្នាំ ២០១០-២០១២</u>** : តាមតួលេខដែល ក.អ.ក/គ.ជ.នា បាន ផ្ទៀងផ្ទាត់ជាមួយដៃគូអភិវឌ្ឍន៍ គិតមកត្រឹមថ្ងៃទី២៩ ខែមេសានេះ រាជរដ្ឋាភិបាលសង្ឃឹមថា អាចកៀរគរបាន ហិរញ្ញប្បទានសហប្រតិបត្តិការ ប្រមាណជាង២.៨០០ លានដុល្លាអាមេរិក សម្រាប់រយៈពេលបីឆ្នាំ២០១០-២០១២ ខាងមុខ នៅក្នុងវេទិកាលើកទី៣ ដូចមានតារាងជូនភ្ជាប់មកជាមួយនេះ ។ តួលេខនេះមិនទាន់បានរាប់បញ្ចូល ធនធានផ្ទាល់ (Core Resource) របស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាលឡើយ ។ ប្រទេសជប៉ុននៅតែ ឈរលំដាប់ទី១ ក្នុងការផ្តល់ហិរញ្ញប្បទានមកកម្ពុជា ដែលមានទំហំច្រើនជាងធនាគារពិភពលោក និងធនាគារ អភិវឌ្ឍន៍អាស៊ី ។ ដៃគូអភិវឌ្ឍន៍ទ្វេភាគីធំៗ បន្ទាប់ពីជប៉ុនមក គឺមានសាធារណៈរដ្ឋប្រជាមានិតចិន ។ តួលេខរបស់ សាធារណៈរដ្ឋប្រជាមានិតចិនអាចទាបជាងការជាក់ស្តែង ពីព្រោះ ម៉្យាងជាទម្លាប់ មិនសូវចេះអួតអាង (Low Profile) ហើយ «និយាយតិច ប៉ុន្តែធ្វើច្រើន» ហើយម៉្យាងទៀត រាជរដ្ឋាភិបាលមានគម្រោងហិរញ្ញប្បទានជាច្រើន ពីសាធារណៈរដ្ឋប្រជាមានិតចិនដែលត្រូវចាប់ផ្តើមអនុវត្តពីឆ្នាំ២០១០នេះតទៅ ។ បន្ទាប់មក គឺប្រទេសអូស្ត្រាលី សាធារណៈរដ្ឋកូរ៉េ និងអាល្លឺម៉ង់ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់ និងសូមមេត្តាពិនិត្យ និងផ្តល់អានុសាសន៍ដ៏ខ្ពង់ខ្ពស់ជាយថាហេតុ តាមការគួរ ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**



**គាត ឈន់**

ចម្លងជូន :

- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ឯកសារ